ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

SOCIAL PROTECTION IN CAMBODIA

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

## ស្តីពី

## ការបើកផ្តល់ប្រាក់ឧបត្ថម្ភជូនបងប្អូនកម្មករនិយោជិតក្នុងវិស័យកាត់ដេរ និងទេសចរណ៍ ដែលត្រូវបានព្យួរកិច្ចសន្យាការងារស្របតាមស្មារតីនៃគោលនយោបាយរបស់រាជរដ្ឋាភិបាល (លើកទី៧៧)

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជូនដំណឹងដល់បងប្អូនកម្មករនិយោជិតចំនួន ១៤ ១៤២នាក់ នៃរោងចក្រ សហគ្រាសទាំង៨៤ នៃវិស័យកាត់ដេរ និងវិស័យទេសចរណ៍ (ដូចមានភ្ជាប់នៅក្នុងឧបសម្ព័ន្ធ) ដែលទទួលបានការអនុញ្ញាតព្យួរកិច្ចសន្យាការងារស្របតាមស្មារតីជុំទី៣នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលជ្រាបថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងផ្ញើសារអំពីការបើកប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាលទៅលេខទូរសព្ទ ដែលបងប្អូនបានផ្តល់មកឱ្យក្រសួងតាមរយៈរដ្ឋបាលរោងចក្រ សហគ្រាសនាពេលកន្លងមក។

ប្រាក់ឧបត្ថម្ភនេះនឹងត្រូវបើកផ្តល់ជាប្រាក់រៀល និងអាស្រ័យលើចំនួនថ្ងៃនៃការព្យួរកិច្ចសន្យាការងារ ក្នុងនោះចំនួន៖

- ៦០ ៧៥០រៀល (១៥ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ៧ថ្ងៃ ដល់ ១០ថ្ងៃ
- ១២១ ៥០០រៀល (៣០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេល ១១ថ្ងៃ ដល់ ២០ថ្ងៃ
- ១៦២ ០០០រៀល (៤០ដុល្លារអាមេរិក) សម្រាប់ការព្យួរកិច្ចសន្យាការងាររយៈពេលចាប់ពី ២១ថ្ងៃ ដល់ ១ខែ។

ក្រសួងសូមរំឭកថា ធនាគារ វីង (ខេមបូឌា) ម.ក នឹងបង្វិលប្រាក់ឧបត្ថម្ភនេះជូនរាជរដ្ឋាភិបាលវិញ ប្រសិនជាបងប្អូនខកខាន មិនបានទៅបើកប្រាក់ឧបត្ថម្ភនេះ ក្នុងរយៈពេល ១០ថ្ងៃ បន្ទាប់ពីទទួលបានសារតាមទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក។ ដើម្បីបើកប្រាក់ឧបត្ថម្ភនេះ បងប្អូនត្រូវយកអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ និងទូរសព្ទដែលទទួលបានសារនោះ ទៅកាន់ភ្នាក់ងារវីងដែលនៅជិតបំផុត។ សូមបញ្ជាក់ថា បងប្អូនមិនតម្រូវឱ្យបង់ថ្លៃសេវាទៅភ្នាក់ងារវីងឡើយពេលបើកប្រាក់ឧបត្ថម្ភនេះ។

ក្នុងករណីបងប្អូនកម្មករនិយោជិត ដែលបម្រើការងារនៅរោងចក្រ សហគ្រាសទាំង៨៤ នេះ មិនបានទទួលសារទូរសព្ទពីធនាគារ វីង (ខេមបូឌា) ម.ក នោះសូមបងប្អូនទំនាក់ទំនងសួរព័ត៌មានបន្ថែម ឬធ្វើបច្ចុប្បន្នភាពលេខទូរសព្ទរបស់ខ្លួន ទៅរដ្ឋបាលរោងចក្រ សហគ្រាសរបស់ខ្លួន។ ក្រសួងនឹងបន្តជូនដំណឹងដល់បងប្អូនកម្មកររោងចក្រ សហគ្រាសដទៃផ្សេងទៀតអំពីការបើកផ្តល់ប្រាក់ឧបត្ថម្ភនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណជន ជាពិសេសបងប្អូនកម្មករនិយោជិតជ្រាបជាព័ត៌មាន និងសូមប្រញាប់ទំនាក់ទំនងបើកប្រាក់ឧបត្ថម្ភនេះនៅតាមភ្នាក់ងារវីងនានាដែលនៅជិតបំផុតឱ្យបានទាន់ពេលវេលា។

ថ្ងៃសុក្រ ៤រោច ខែបុស្ស ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២២

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**
**គណៈកម្មការអនុវត្តវិធានការរាជរដ្ឋាភិបាល**

### ឧបសម្ព័ន្ធ នៃសេចក្តីជូនដំណឹងចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០២២

### បញ្ជីឈ្មោះ រោងចក្រ សហគ្រាស ក្នុងវិស័យកាត់ដេរ និងវិស័យទេសចរណ៍ ចំនួន ៨៤ ដែលទទួលបានប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ក. វិស័យកាត់ដេរ | | 18 |
| 1 | ក្រុមហ៊ុន ហាណា (ខេមបូឌា) អ៊ីង | ភ្នំពេញ |
| 2 | ក្រុមហ៊ុន ហ្គូ តែ សេងស៊ីង ( ខេមបូឌា ) ហ្គាមិន ខូអិលធីឌី | ភ្នំពេញ |
| 3 | ក្រុមហ៊ុន ឌី សិតា (ខេមបូឌា) ឯ.ក | ភ្នំពេញ |
| 4 | ក្រុមហ៊ុន គ្លូរី នីត វែរ អិលធីឌី | កណ្តាល |
| 5 | ក្រុមហ៊ុន វ៉ាយ អិម ជី ហ្គាមេន អេកសេស៊េរី | កណ្តាល |
| 6 | ក្រុមហ៊ុន ញូ អេរ៉ា (ខេមបូឌា) ខាសម៉ៀ ថិកស្ដាយ៍ ឯ.ក | កណ្តាល |
| 7 | ក្រុមហ៊ុន មូនតៃ ខេជេ (ខេមបូឌា) ខូអិលធីឌី | កណ្តាល |
| 8 | ក្រុមហ៊ុន នីអូ មេរីខាន អ៊ិនដាសស្ទ្រី ហ្គាមេន(ខេមបូឌា)ឯ.ក | កណ្តាល |
| 9 | ក្រុមហ៊ុន ហ្គោលហ្វេម ស្តារ អេនធើប្រាយ (ខេមបូឌា) លីមីធីត | កណ្តាល |
| 10 | ក្រុមហ៊ុន ប្រាយ ហ្វាស់ស៊ីង ឯ.ក | តាកែវ |
| 11 | ក្រុមហ៊ុន ហ្វ្រេសហ្វូល(ខេមបូឌា)ថេកស្ទាយ ខូ.អិលធីឌី | តាកែវ |
| 12 | ក្រុមហ៊ុន សុហ្សេន(ខេមបូឌា)អ៊ិនដាសស្ទ្រៀលឯ.ក | ត្បូងឃ្មុំ |
| 13 | ក្រុមហ៊ុន ថបស៊ីលវើរ លីមីធីត (សាខាទី1) | ត្បូងឃ្មុំ |
| 14 | ក្រុមហ៊ុន ថប ស៊ីលវើរ លីមីធីត | ព្រៃវែង |
| 15 | ក្រុមហ៊ុន អរិន មេនូហ្វេកឆឺរីង ( ខ្មែរ ) | ព្រៃវែង |
| 16 | ក្រុមហ៊ុន ស៊ូភើ លីង ហ្វេសិន (ខេមបូឌា)ឯ.ក | កំពង់ឆ្នាំង |
| 17 | ក្រុមហ៊ុន អ៊ែដ្យាយល៍ ស្វេតធី(ខេមបូឌា)ខូ អិលធីឌី | កំពង់ស្ពឺ |
| 18 | ក្រុមហ៊ុន យ៉កស៍(ខេមបូឌា) ខូអិលធីឌី | ស្វាយរៀង |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| ខ. វិស័យទេសចរណ៍ | | 66 |
| 19 | ក្រុមហ៊ុន ឡឺ ប្រេស៊ីដង់អូតែល-កូបេ | ភ្នំពេញ |
| 20 | សណ្ឋាគារ អូឡាំព្យា ស៊ីធី ហូថេល | ភ្នំពេញ |
| 21 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 22 | ក្រុមហ៊ុន អលមិន ខូ អិលធីឌី | ភ្នំពេញ |
| 23 | សណ្ឋាគារ រ៉េស៊ីដង់ សុខា ភ្នំពេញ | ភ្នំពេញ |
| 24 | ក្រុមហ៊ុន ហ៊្វូដឡាយហ្វ៍ ឯ.ក | ភ្នំពេញ |
| 25 | ក្រុមហ៊ុន វើលដ៍ ដាយនីង លីមីធីត | ភ្នំពេញ |
| 26 | ក្រុមហ៊ុន អិល&អិម បាសាក់ រីវើរ ខូ អិលធីឌី | ភ្នំពេញ |
| 27 | ក្រុមហ៊ុន អលគ្រីម (ខេមបូឌា) ខូ អិលធីឌី | ភ្នំពេញ |
| 28 | ក្រុមហ៊ុន រ៉េមប៊ូធិនរីសតខេមបូឌាន | ភ្នំពេញ |
| 29 | សណ្ឋាគារ ភ្នំពេញ អេរ៉ា ហូថេល ឯ.ក | ភ្នំពេញ |
| 30 | ក្រុមហ៊ុន អាយរ៉ុន ឆេហ្វ អេហ្វ&ប៊ី (ខេមបូឌា)ឯ.ក | ភ្នំពេញ |
| 31 | សណ្ឋាគារ ហ្គាឌិន ស៊ីធី ហូថេល | ភ្នំពេញ |
| 32 | ក្រុមហ៊ុន សិប្បករអង្គរ ភ្នំពេញ | ភ្នំពេញ |
| 33 | ក្រុមហ៊ុន ដារ៉ា អ៊ែរផត ហូថេល | ភ្នំពេញ |
| 34 | ក្រុមហ៊ុន រ៉ាហ្វលមហាសណ្ឋាគារអង្គរ | សៀមរាប |
| 35 | ក្រុមហ៊ុន ដឺ សុទ្ធា (ខេ.វី) ភីធីអ៊ី អិលធីឌី | សៀមរាប |
| 36 | ក្រុមហ៊ុន មុទិតា រីសត & ស្ប៉ា | សៀមរាប |
| 37 | ផ្ទះសំណាក់ សាតូអង្គ | សៀមរាប |
| 38 | ក្រុមហ៊ុន GB II Co., LTD | សៀមរាប |
| 39 | ក្រុមហ៊ុន រេសចឺរេន ខូឡិចហ្សិន | សៀមរាប |
| 40 | ក្រុមហ៊ុន បា ឡឺ កូដ គ្រេឌីង | សៀមរាប |
| 41 | ក្រុមហ៊ុន កូបេ យៃភែននីស រ៉េស្តូរ៉ង់ | សៀមរាប |
| 42 | ភោជនីយដ្ឋាន វីវ៉ា | សៀមរាប |
| 43 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេមេគង្គ) | សៀមរាប |
| 44 | ក្រុមហ៊ុន ទន្លេសាបចៅផាយ៉ា( ភោជនីយដ្ឋានទន្លេសាប) | សៀមរាប |
| 45 | ក្រុមហ៊ុន ហ្វូឌីស អេស៊ា អ៊ីនធើណេសិនណលត្រាវ៉ែល ស៊ីវីស | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 46 | ក្រុមហ៊ុន សិប្បករអង្គរ | សៀមរាប |
| 47 | សណ្ឋាគារ តាព្រហ្ម | សៀមរាប |
| 48 | សណ្ឋាគារសុខាល័យអង្គរ រីហ្សត និងស្ប៉ា | សៀមរាប |
| 49 | សណ្ឋាគារ អូរៀនថល ជេ7 | សៀមរាប |
| 50 | ក្រុមហ៊ុន ព្រីនសៅ រីហ្សត (អាម៉ាន់សារា) | សៀមរាប |
| 51 | សណ្ឋាគារ ស្មាយលីង | សៀមរាប |
| 52 | ក្រុមហ៊ុន អង្គរតែលេសរីហ្សត និងស្ប៉ា | សៀមរាប |
| 53 | សណ្ឋាគារសុខាសៀមរាប | សៀមរាប |
| 54 | សណ្ឋាគារស្ទឹងសៀមរាបថ្មី | សៀមរាប |
| 55 | សណ្ឋាគារ សុខាអង្គរ | សៀមរាប |
| 56 | ក្រុមហ៊ុន ហ្គោលដេន ទ្រី ព្រីនស៍ ហូថែល និងស្ប៉ា | សៀមរាប |
| 57 | ក្រុមហ៊ុន ដំរីអង្គរ ខូ អិលធីឌី | សៀមរាប |
| 58 | សណ្ឋាគារ រីចេនស៊ីអង្គរ | សៀមរាប |
| 59 | សណ្ឋាគារខេមរាអង្គរ | សៀមរាប |
| 60 | សណ្ឋាគារដឺឡាពេ (ផាកហៃយ៉ាត់សៀមរាប) | សៀមរាប |
| 61 | សណ្ឋាគារ ប៉ាស៊ីហ្វិក | សៀមរាប |
| 62 | សណ្ឋាគារ ហិមា ប៊ូទិក | សៀមរាប |
| 63 | ក្រុមហ៊ុន សាបារា អង្គរ រីសត និង ស្ប៉ា | សៀមរាប |
| 64 | សណ្ឋាគារ អង្គរ | សៀមរាប |
| 65 | សណ្ឋាគារ អង្គរប៉ារ៉ាឌី | សៀមរាប |
| 66 | សណ្ឋាគារ សាងមសៀមរាប | សៀមរាប |
| 67 | សណ្ឋាគារ លីនាយាអង្គរ រីសត និងស្ប៉ា | សៀមរាប |
| 68 | ក្រុមហ៊ុន រ៉ូយ៉ាល់អង្គរ (សណ្ឋាគារសូហ្វីតែលអង្គរភូគីត្រាហ្គោហ្វ & ស្ប៉ារីហ្សត) | សៀមរាប |
| 69 | ក្រុមហ៊ុន បាហ្វីឡូធូរ (ខេមបូឌា) លីមីតធីត | សៀមរាប |
| 70 | ក្រុមហ៊ុន អឹបៅអេស៊ា | សៀមរាប |
| 71 | ក្រុមហ៊ុន ម៉េម៉រអង្គរ (ខេមបូឌា) | សៀមរាប |
| 72 | សណ្ឋាគារ តារា អង្គរ | សៀមរាប |
| 73 | សណ្ឋាគារ សារ៉ៃរីសត និង ស្ប៉ា | សៀមរាប |

| ល.រ | ឈ្មោះរោងចក្រ សហគ្រាស | រាជធានី ខេត្ត |
|---|---|---|
| 74 | ក្រុមហ៊ុន ដី អេវៀរី | សៀមរាប |
| 75 | ភោជនីយដ្ឋានចាន់រីទ្រី | សៀមរាប |
| 76 | សណ្ឋាគារទ្រីឡាញ អីបេន រីហ្សត | សៀមរាប |
| 77 | ក្រុមហ៊ុន អេប៊ិច ខេមបូឌា ត្រាវ៉េល សើរវីស | សៀមរាប |
| 78 | សណ្ឋាគារ វីណាហ្គហ្វ អង្គរ | សៀមរាប |
| 79 | ក្រុមហ៊ុន អេវីតាស II | សៀមរាប |
| 80 | ក្រុមហ៊ុន ភូមិបៃតង (ខេមបូឌា) | សៀមរាប |
| 81 | ក្រុមហ៊ុន ខ្មែរអង្គរហូថែលកូអិលធីឌី | សៀមរាប |
| 82 | រមណីយដ្ឋានឆ្នេរសុខា | ព្រះសីហនុ |
| 83 | ក្រុមហ៊ុន អ៊ិនឌីភែនដឹនថ៍ ហូថេល | ព្រះសីហនុ |
| 84 | ក្រុមហ៊ុន ថ្មរូង ឌីវេឡុបមេន | ព្រះសីហនុ |